00654989

E23/3

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ** ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

**ភាគីដាក់ឯកសារ** ៖មេធាវីការពារក្តី អៀង សារី

**ដាក់ជូន** ៖ អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម** ៖ អង់គ្លេស

**កាលបរិច្ឆេទឯកសារ** ៖ ៩ មីនា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ៖ **សាធារណៈ / Public**

ប្រភេទនៃចំណាត់ថ្នាក់ ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់

បណ្តោះអាសន្ន ៖

ឈ្មោះមន្ត្រីកត់ត្រា ៖

ហត្ថលេខា ៖

---

**ការឆ្លើយតបរបស់ អៀង សារី ចំពោះចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះញត្តិរបស់គាត់ស្នើសុំឲ្យបង្កើតសេចក្តីណែនាំស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង យូរ ឧត្តរ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 17 / 03 / 2011
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក អៀង សារី តាមរយៈមេធាវីការពារក្ដីរបស់ខ្លួន ("មេធាវីការពារក្ដី") សូមឆ្លើយតបទៅនឹងចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ("ចម្លើយតប")[១] ចំពោះញត្តិរបស់លោកស្នើសុំឱ្យបង្កើតសេចក្ដីណែនាំស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ("ញត្តិ")[២]។ ការឆ្លើយតបនេះត្រូវធ្វើឡើងជាចាំបាច់ ពីព្រោះចម្លើយតបមានភាពមិនត្រូវមួយចំនួន ដែលត្រូវកែតម្រូវជាចាំបាច់។ មេធាវីការពារក្ដីបន្តស្នើថា បញ្ហានេះត្រូវតែយកទៅពិភាក្សានៅឯកិច្ចប្រជុំរៀបចំសវនាការ ដែលគ្រោងធ្វើនៅខែ មេសា ឆ្នាំ ២០១១[៣] ដើម្បីឱ្យភាគីទាំងអស់បញ្ចេញទស្សនៈរបស់ខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

**I. មេធាវីការពារក្ដីទទួលបានការអនុញ្ញាតឱ្យដាក់ឯកសារចំនួន ១៥ ទំព័រទៅអង្គជំនុំជម្រះសាលាដំបូង**

១. សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ("សេចក្ដីណែនាំអនុវត្ត") អនុញ្ញាតឱ្យដាក់ការឆ្លើយតប "ត្រូវដាក់ក្នុងរយៈពេល ៥ថ្ងៃនៃប្រតិទិន គិតពីថ្ងៃជូនដំណឹងនៃចម្លើយតបនោះ ដោយប្រើប្រាស់ភាសាផ្លូវការរបស់ អ.វ.ត.ក ហើយជាភាសាដែលភាគីបានជ្រើសរើសដើម្បីឆ្លើយតប យោងតាមមាត្រា ២.២"[៤]។ មេធាវីការពារក្ដីបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា ភាសាផ្លូវការរបស់ខ្លួនក្នុងការឆ្លើយតបគឺភាសាខ្មែរ និងភាសាអង់គ្លេស[៥]។ មេធាវីការពារក្ដីបានទទួលការជូនដំណឹងពីការដាក់ចម្លើយតបជាភាសាអង់គ្លេសនៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១១។ ពេលវេលាកំណត់សម្រាប់ការដាក់ចម្លើយតបនេះគឺមានចំនួន ៥ថ្ងៃ រាប់ពីថ្ងៃនៃការជូន

[១] *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/អជសដ ចម្លើយតបទៅនឹងញត្តិរបស់លោក អៀង សារី សុំឱ្យបង្កើតសេចក្ដីណែនាំស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E23/2 ERN: 00649092-00649100។

[២] *រឿងក្ដី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ ញត្តិរបស់ អៀង សារី ស្នើសុំការណែនាំអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារ E23 ERN: 00637283-00637291។

[៣] *រឿងក្ដី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ អនុស្សរណៈអន្តរការិយាល័យ ពីអ្នកស្រី Susan LAMB មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនគ្រប់ភាគីទាំងអស់នៃសំណុំរឿង០០២ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/5 ERN: 00641511-00641511។

[៤] សេចក្ដីណែនាំអនុវត្ត មាត្រា៨.៥។

[៥] *រឿងក្ដី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ សេចក្ដីជូនដំណឹងរបស់ អៀង សារី ទៅក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងដើម្បីដាក់ និងទទួលឯកសារទាំងអស់ជាភាសាខ្មែរ និងអង់គ្លេស ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១១ ឯកសារ E22 ERN: 00637277-00637278។

ដំណឹង[៦]។ ថ្ងៃទី ៥ និងថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១១ គឺជាថ្ងៃចុងសប្តាហ៍ ហើយថ្ងៃទី ៨ ខែមីនា ឆ្នាំ ២០១១ គឺជាថ្ងៃឈប់សម្រាកនៅថ្ងៃបុណ្យជាតិ។ នៅក្នុងថ្ងៃទាំងនេះ អង្គភាពបកប្រែភាសាមិនធ្វើការឡើយ។ នៅពេលដកថ្ងៃសម្រាកបុណ្យជាតិ ថ្ងៃទី ៨ ខែមីនា ឆ្នាំ ២០១១ ចេញពេលវេលាកំណត់សម្រាប់ការឆ្លើយតបនេះ គឺថ្ងៃទី ៩ ខែមីនា ឆ្នាំ ២០១១[៧]។ ដោយសារតែភាពជាប់គាំងក្នុងការបកប្រែ និងពេលវេលាកំណត់ខ្លី នៅថ្ងៃទី ៨ ខែមីនា ឆ្នាំ ២០១១ មេធាវីការពារក្តីបានស្នើសុំថា ខ្លួននឹងដាក់ការឆ្លើយតបជាភាសាអង់គ្លេសមុន ហើយដាក់ការឆ្លើយតបនេះជាភាសាខ្មែរនៅពេលបកប្រែរួចភ្លាម។ លោកស្រី Susan Lamb មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងបានសម្រេចឯកភាពនឹងសំណើនេះ ប៉ុន្តែបានបញ្ជាក់ថា ការឆ្លើយតបនេះត្រូវបានអនុញ្ញាតតែចំនួន ៥ ទំព័រជាភាសាអង់គ្លេសប៉ុណ្ណោះ។ ការកម្រិតចំនួនទំព័រនេះ គឺផ្ទុយទៅនឹងសេចក្តីណែនាំអនុវត្តដែលចែងថា ឯកសារទាំងអស់ ដែលត្រូវដាក់ទៅអង្គជំនុំជម្រះសាលាដំបូងអាចធ្វើឡើងរហូតដល់ ១៥ ទំព័រជាភាសាអង់គ្លេស។ អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់ដីកា ឬសេចក្តីសម្រេចផ្លូវការណាមួយទាក់ទងនឹងការរឹតត្បិតចំនួនទំព័រនេះឡើយ គឺមានតែសារអេឡិចត្រូនិកមួយគត់ពីមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះនេះប៉ុណ្ណោះ។ សារអេឡិចត្រូនិកនេះពុំមានឃើញចុះហត្ថលេខាដោយចៅក្រមណាម្នាក់ឡើយ។ មេធាវីការពារក្តីពុំបានទទួលការផ្តល់សំអាងហេតុចំពោះការរឹតត្បិតនេះពីអង្គជំនុំជម្រះសាលាដំបូង ឬពីមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ទេ។ មេធាវីការពារក្តីក៏មិនបានទទួលការផ្តល់សំអាងហេតុថា ហេតុអ្វីបានជាការរឹតត្បិតចំនួនទំព័រនេះត្រូវបានជូនដំណឹងដល់មេធាវីការពារក្តីក្នុងរយៈពេលតែមួយថ្ងៃគត់ មុនពេលពេលវេលាកំណត់នៃការដាក់ឯកសារ។ ដើម្បីគោរពតាមសេចក្តីណែនាំអនុវត្តជាផ្លូវការ និងដោយមិនអនុវត្តតាមសារអេឡិចត្រូនិក ដែលគ្មានសំអាងហេតុពី

---

[៦] *រឿងក្តី នួន ជា* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/អជសង អនុស្សរណៈអន្តរការិយា ពីលោកស្រី Susan LAMB មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនគ្រប់ភាគីទាំងអស់នៃសំណុំរឿង០០២ ការកំណត់ពេលវេលាសម្រាប់ដាក់ពាក្យសុំនិងការឆ្លើយតបនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E45 ERN: 00644019-00644019។

[៧] វិធាន៣៩ ចែងថា៖ “គ្រប់ពេលវេលាកំណត់ទាំងអស់ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ ត្រូវផុតកំណត់នៅថ្ងៃចុងក្រោយវេលាម៉ោង២៤:00 នៅកម្ពុជាលើកលែងតែមានចែងផ្សេងនៅក្នុងវិធានផ្ទៃក្នុងនេះ។ កាលបើពេលវេលាកំណត់ត្រូវបន្តជាស្វ័យប្រវត្តិទៅថ្ងៃធ្វើការបន្ទាប់។”

មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ មេធាវីការពារក្ដីសូមដាក់ការឆ្លើយតបជាភាសាអង់គ្លេស ដែលមានចំនួនទំព័រមិនលើសពី ១៥ទំព័រជាភាសាអង់គ្លេសនេះ[៨]។

## II. ការឆ្លើយតប

២. នៅក្នុងកថាខណ្ឌ ១ ដើមបណ្ដឹងរដ្ឋប្បវេណីមានការភ័ន្តច្រឡំក្នុងការអះអាងរបស់ខ្លួនថា ញត្តិនេះមិនមែនជាលិខិតគតិយុត្ត និងថា ញត្តិនេះ “មិនអាចទុកថាជាលិខិតគតិយុត្ត ឬជាសារណាឡើយ បើផ្អែកតាមមាត្រា ៨នៃសេចក្ដីណែនាំអនុវត្តរបស់ អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៥”[៩]។ វិធាន ៩២ បានលើកឡើងនៅក្នុងផ្នែកពាក់ព័ន្ធថា “រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ភាគីអាចធ្វើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដូចមានចែងនៅក្នុងសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ”។ មាត្រា ៨ នៃសេចក្ដីណែនាំអនុវត្ត ស្ដីពីការដាក់ឯកសារនៅចំពោះមុខរបស់ អ.វ.ត.ក ចែងតែពីពេលវេលាកំណត់សម្រាប់ការដាក់លិខិតគតិយុត្ត និងសារណានៅចំពោះមុខអង្គជំនុំជម្រះប៉ុណ្ណោះ ហើយមាត្រានេះមិនចែងពីលិខិតគតិយុត្ត ឬសារណាឡើយ។ ញត្តិនេះបំពេញលក្ខខណ្ឌទាំងអស់នៃលិខិតគតិយុត្ត ហើយត្រូវចាត់ទុកជាលិខិតគតិយុត្ត។

៣. នៅក្នុងកថាខណ្ឌ ១ នេះដែរ ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់បន្ថែមទៀតថា “លោក អៀង សារី ស្នើសុំឱ្យដាក់កម្រិតដល់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី តាមរយៈសេចក្ដីណែនាំ ដែលត្រូវបង្កើតឡើងនៅមុនពេលជំនុំជម្រះក្ដី ក្រោមទម្រង់ជាសេចក្ដីណែនាំអនុវត្ត”។ មេធាវីការពារក្ដីធ្វើការបញ្ជាក់ថា ដើមបណ្ដឹងរដ្ឋប្បវេណីពិតជាមានតួនាទីចាំបាច់ នៅ អ.វ.ត.ក ដូចមានបញ្ជាក់ជាច្រើនដងពីមុនៗមក[១០] រួមទាំងការបញ្ជាក់នៅក្នុងញត្តិនេះផង[១១]។ ផ្ទុយទៅនឹងចម្លើយតបនេះ[១២]

---

[៨] *សូមមើលផងដែរ រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/អជសដ សេចក្ដីសង្ខេបអញ្ញត្រកម្មតាមវិធាន៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានាពេលអនាគត ដែលត្រូវបានចេញជំនួសឱ្យសេចក្ដីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E51/4 ERN: 00648370-00648385។

[៩] ចម្លើយតប កថាខណ្ឌ១។

[១០] *សូមមើលជាឧទាហរណ៍ រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១០១) ចម្លើយតបរបស់ អៀង សារី ចំពោះបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីប្រឆាំងនឹងការបដិសេធដោយ កសចស លើការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D399/2/2 ERN: 00612145-00612147។

[១១] ញត្តិ សេចក្ដីផ្ដើម។

មេធាវីការពារក្តី មិនធ្លាប់ស្នើដល់អង្គជំនុំជម្រះសាលាដំបូងឱ្យដាក់កម្រិតដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃការជំនុំជម្រះក្តីឡើយ។ ផ្ទុយទៅវិញ មេធាវីការពារក្តីបានស្នើដល់អង្គជំនុំជម្រះសាលាដំបូង ឱ្យបង្កើតសេចក្តីណែនាំសម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃការជំនុំជម្រះក្តី "ដើម្បីធានាថា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានភាពសមស្របទៅនឹងតួនាទីជាក់លាក់របស់ខ្លួនក្នុងដំណើរការនីតិវិធី"[១៣]។ កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[១៤] ពុំមានចែងពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ឡើយ។ ទោះបីវិធានខ្លះចែងថា វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺដើម្បីជួយគាំទ្រដល់ការចោទប្រកាន់ និងទាមទារសំណងផ្លូវចិត្ត និងសំណងសមូហភាពក៏ដោយ ក៏អត្ថន័យជាក់ច្បាស់នៃ "ការជួយគាំទ្រដល់ការចោទប្រកាន់" មិនត្រូវបានចែងឡើយ[១៥]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អត្ថន័យនៃការគាំទ្រដល់ការចោទប្រកាន់ "ត្រូវតែបកស្រាយក្នុងន័យចង្អៀត និងមិនផ្តល់សិទ្ធិទូទៅនៃការចូលរួមស្មើភាពគ្នាជាមួយសហព្រះរាជអាជ្ញានោះទេ"[១៦]។ ទាក់ទងនឹងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលជំនុំជម្រះក្តី វិធានគ្រាន់តែកំណត់យ៉ាងច្បាស់ថា សកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវកម្រិតត្រឹមតែផលប្រយោជន៍ ស៊ីវិលរបស់ខ្លួននៅក្នុងអំឡុងពេលនៃការជំនុំជម្រះក្តីប៉ុណ្ណោះ[១៧]។ សម្រាប់ជួយដល់គោលបំណងនៃកិច្ចដំណើរការ

---

[១២] សេចក្តីឆ្លើយតប កថាខណ្ឌ១។

[១៣] ញត្តិ សេចក្តីផ្តើម។

[១៤] មាត្រា៣៦ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក ផ្តល់ឱ្យ "ជនរងគ្រោះ" នូវសិទ្ធិបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

[១៥] វិធាន២៣(១) ចែងថា៖ "គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញគឺដើម្បី៖ ក)ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង។ ខ)ទាមទារសំណងផ្លូវចិត្ត និងសមូហភាព ដូចមានចែងក្នុងវិធាន២៣ *ស្ទួនបួន*។"

[១៦] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អវតក/អជសង សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ E72/3 ERN: 00387022-00387047 ("សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១") កថាខណ្ឌ២៥។

[១៧] វិធាន៨០ស្ទួន(៤) ចែងថា៖ "[នៅសវនាការបឋម] អង្គជំនុំជម្រះសាលាដំបូង អាចណែនាំសហមេធាវីនាំមុខឱ្យផ្តល់ខ្លឹមសារជាក់លាក់ស្តីពីសំណងដែលខ្លួនមានបំណងស្នើសុំនៅក្នុងបណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្ត និងសមូហភាពក្នុង

នីតិវិធី ទាំងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[១៨] ទាំងក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មិនមិនបានចែងច្បាស់សម្រាប់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីបំពេញតួនាទីគាំទ្រដល់ការចោទប្រកាន់ ហើយក៏មិនអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណី មានវេទិកាសម្រាប់ធ្វើការបញ្ចេញមតិលើពិរុទ្ធភាពរបស់ជនជាប់ចោទ ឬសពីការបង្ហាញទំនាក់ទំនងរវាងអំពីរបស់ជនជាប់ចោទ និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ[១៩]។ ញត្តិនេះបានស្នើដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបង្កើតសេចក្តីណែនាំដែលមានការឆ្លុះបញ្ចាំងយ៉ាងច្បាស់លាស់ពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងនៅក្នុងច្បាប់ជាធរមាននៅ អ.វ.ត.ក។

៤. នៅក្នុងកថាខណ្ឌ ២ ដើមបណ្តឹងរដ្ឋប្បវេណីមានការភ័ន្តច្រឡំក្នុងការអះអាងរបស់ខ្លួនថា "លក្ខណៈអនីត្យានុកូលនៃសេចក្តីណែនាំបែបនេះ និងការប៉ះពាល់ដល់សិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានស្តែងឡើងយ៉ាងច្បាស់ក្រឡែតតែម្តង"។ ទីមួយ មេធាវីការពារក្តីបានស្នើនៅក្នុងញត្តិដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបង្កើតសេចក្តីណែនាំ។ មេធាវីការពារក្តីបានស្នើឱ្យពិចារណាលើសំណូមពរជាច្រើន នៅពេលបង្កើតសេចក្តីណែនាំទាំងនេះ។ ដូចមានការពន្យល់នៅក្នុងបញ្ជីដែលមានភ្ជាប់មកខាងក្រោម សំណូមពរទាំងនេះត្រូវបានធ្វើឡើងដោយផ្អែកលើច្បាប់ជាធរមាននៅ អ.វ.ត.ក និង/ឬមានបង្ហាញនៅក្នុងយុត្តិសាស្ត្ររបស់ អ.វ.ត.ក។ ដូចនេះ សេចក្តីណែនាំទាំងនេះមិនអាចចាត់ទុកថាជាសេចក្តីណែនាំខុសច្បាប់ឡើយ។

ក. **ដាក់កម្រិតការអន្តរាគមន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីតែលើបញ្ហានានាដែលចូលរួមចំណែកក្នុងការស្វែងរកការពិត**។ វិធាន ៨៥(១) ចែងថា "ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវដឹកនាំកិច្ចដំណើរការនីតិវិធី និងជួយសម្រួលដល់ការធ្វើអន្តរាគមន៍របស់ចៅក្រមផ្សេងៗទៀត។ ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឱ្យប្រព្រឹត្តទៅដោយសេរី។ ដោយមានការពិគ្រោះ

---

អំឡុងពេលមួយជាក់លាក់ដែលបានកំណត់ដោយអង្គជំនុំជម្រះដោយអនុលោមតាមវិធាន២៣*ស្ទួនបួន*(៣)(ខ)។ នៅដំណាក់កាលក្រោយមកទៀត អង្គជំនុំជម្រះនឹងត្រូវកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់សហមេធាវីនាំមុខក្នុងការដាក់បណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្ត និងសមូហភាព។" (គូសបញ្ជាក់បន្ថែម)។

[១៨] *សូមមើល* CPC មាត្រា១៣-២៦, ៣៣៤-៣៥ ដែលបានផ្តោតទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែមួយគត់ ទៅនឹងអត្ថប្រយោជន៍នៃសំណងរបស់ពួកគេ។

[១៩] *សូមមើល* CATHERINE ELLIOTT, ក្រមព្រហ្មទណ្ឌបារាំង 32-33 (Willan Publishing, 2001)។

00654995



យោបល់ជាមួយចៅក្រមផ្សេងទៀត ប្រធានសវនាការអាចបដិសេធនូវរាល់នីតិវិធី ដែលនាំឱ្យមានការពន្យារពេលដល់ការជំនុំជម្រះក្តី និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត"[២០]។

ខ. **ដាក់កម្រិតការអន្តរាគមន៍ពីដើមបណ្តឹងរដ្ឋប្បវេណីចំពោះបញ្ហានានាដែលពាក់ព័ន្ធទាំងការចោទប្រកាន់ និងទាំងផលប្រយោជន៍នៃដើមបណ្តឹងរដ្ឋប្បវេណី និងសម្រាប់គោលបំណងបង្ហាញពីព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី**។ វិធាន ៨០*ស្ទួន*(៤) ចែងថា "[នៅពេលបើកសវនាការបឋម]អង្គជំនុំជម្រះសាលាដំបូងអាចណែនាំសហមេធាវីនាំមុខឱ្យផ្តល់ខ្លឹមសារជាក់លាក់ស្តីពីសំណងដែលខ្លួនមានបំណងស្នើសុំក្នុងបណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្ត និងសម្ភារភាព ក្នុងអំឡុងពេលកំណត់មួយជាក់លាក់ដែលបានកំណត់ដោយអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន២៣*ស្ទួន*បួន(៣)(ខ)។ នៅដំណាក់កាលក្រោយមកទៀត អង្គជំនុំជម្រះនឹងត្រូវកំណត់កាលបរិច្ឆេទសម្រាប់សហមេធាវីនាំមុខក្នុងការដាក់បណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្ត និងសម្ភារភាព]"[២១]។ មាត្រា ១៣ ដល់មាត្រា ២៦ និងមាត្រា ៣៣៤ ដល់មាត្រា ៣៣៥នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (CPC) ចែងពី តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី តែក្នុងករណីទាក់ទងនឹងផលប្រយោជន៍សំណងរបស់ខ្លួនប៉ុណ្ណោះ។

គ. **ដាក់កម្រិតការអន្តរាគមន៍ពីដើមបណ្តឹងរដ្ឋប្បវេណីលើបញ្ហានានា ដែលមិនសមស្របជាមួយនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងឥតលំអៀង**។ មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងចែងថា "សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ["ICCPR"]ត្រូវតែគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះ ជាពិសេស ដោយរួមទាំងសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ ..."[២២]។ មាត្រា ១៤(១)នៃ ICCPR ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា "ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើ

---

[២០] គូសបញ្ជាក់បន្ថែម។

[២១] គូសបញ្ជាក់បន្ថែម។

[២២] គូសបញ្ជាក់បន្ថែម។

00654996



ខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី"[២៣]។ វិធាន ២១(១)(ក)នៃវិធានផ្ទៃក្នុងចែងក្នុងផ្នែកដែលពាក់ព័ន្ធថា "កិច្ចដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងគោរពតាមគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបានតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

ឃ. **ដាក់កម្រិតការអន្តរាគមន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីលើបញ្ហានានា ដែលនឹងមិនបង្កើតផលប៉ះពាល់អវិជ្ជមាន លើការពន្លឿនកិច្ចដំណើរការនីតិវិធី**។ វិធាន ២១(៤)នៃវិធានផ្ទៃក្នុងចែងថា "ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប"។ វិធាន ១៣(៣)(គ)នៃ ICCPR ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ៖ ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួស"។

ង. **រឹតត្បិតដល់ដើមបណ្តឹងរដ្ឋប្បវេណីពីការធ្វើសេចក្តីសន្និដ្ឋានស្តីពីការផ្តន្ទាទោស** ។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ យល់ឃើញថា "វិធាន ២៣(១)(ក)នៃវិធានផ្ទៃក្នុង ... មិនបានចែង ... អំពីមូលដ្ឋានច្បាប់សម្រាប់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឱ្យធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសទេ"[២៤]។

ច. **រឹតត្បិតដល់ដើមបណ្តឹងរដ្ឋប្បវេណីពីការសាកសួរសាក្សី អ្នកជំនាញ ឬជនជាប់ចោទ ពីអត្តចរិតជនជាប់ចោទសម្រាប់ការផ្តន្ទាទោស**។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ដើមបណ្តឹងរដ្ឋប្បវេណីជាទូទៅមិនអាចតាំងសំណួរដល់ជនជាប់ចោទ ដែលទាក់ទងនឹងអត្តចរិតរបស់គាត់បានទេ។ អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចសួរអ្នកជំនាញ និងសាក្សីនានា ដែលត្រូវផ្តល់សក្ខីកម្មតែអំពីអត្តចរិតជនជាប់ចោទ"[២៥] ឡើយ។

---

[២៣] គូសបញ្ជាក់បន្ថែម។

[២៤] សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ កថាខណ្ឌ៣៥។

[២៥] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៨។

ទីពីរ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានបញ្ជាក់ថាតើញត្តិនេះបំពានលើសិទ្ធិរបស់ខ្លួនមួយណាឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីមានការភ័ន្តច្រឡំថែមទៀតក្នុងការអះអាងថា "សំណើរបស់មេធាវីការពារក្តីធ្វើឡើងដោយផ្តើមចេញពីការយល់ច្រលំ .... លើនីតិវិធីជាធរមាន ស្របតាមប្រព័ន្ធច្បាប់ Civil Law"។ ដូចមានបញ្ជាក់ខាងលើស្រាប់ មេធាវីការពារក្តីបានស្នើអង្គជំនុំជម្រះសាលាដំបូងឲ្យបង្កើតសេចក្តីណែនាំ និងបានធ្វើសំណូមពរ ស្របទៅនឹងច្បាប់ជាធរមាននៅ អ.វ.ត.ក។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតសេចក្តីណែនាំ ដោយធ្វើការបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថាការងារនេះគឺជាស្ថិតនៅក្នុងតួនាទីរបស់ខ្លួន[២៦]។ ច្បាស់ណាស់ អង្គជំនុំជម្រះសាលាដំបូង មាននីតិវិធីសម្រាប់បង្កើតសេចក្តីណែនាំដើម្បីធានាឲ្យដំណើរការជំនុំជម្រះមានភាពរលូន និងមានប្រសិទ្ធភាព។ វាជារឿងធម្មតាទេដែលថា ក្នុងការជំនុំជម្រះរឿងក្តីកម្រិតនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវបង្កើតសេចក្តីណែនាំសម្រាប់ដំណើរការជំនុំជម្រះក្តីនេះ[២៧]។

៥. នៅក្នុងកថាខណ្ឌ ២ ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា "ភាគីទាំងអស់ទទួលបាននូវសមភាព និងស្វ័យភាពដូចគ្នា ដែលជាសិទ្ធិមួយត្រូវបានការការពារ ដោយគ្មានការរើសអើង"។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់បន្ថែមក្នុងកថាខណ្ឌ ២ ទៀតថា "ដើមបណ្តឹងរដ្ឋប្បវេណី ដែលតំណាងដោយមេធាវីរបស់ខ្លួន មានសិទ្ធិចូលរួមនៅគ្រប់ដំណាក់កាលនៃនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក្នុងនាមជាភាគីនៃរឿងក្តី ហើយក្នុងឋានៈនេះ ដើមបណ្តឹងរដ្ឋប្បវេណីទទួលបាននូវសិទ្ធិស្មើគ្នាជាមួយនឹងភាគីដទៃទៀត ដែលសិទ្ធិនេះត្រូវបានចែងដោយច្បាប់ និងមិនត្រូវបានលើកយកមកចោទជាបញ្ហាឡើយ"។ វាពុំមានជាបញ្ហាអ្វីឡើយ ដែលថា ដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីនៃកិច្ចដំណើរការនីតិវិធី។ ជនជាប់ចោទមានតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ៖ ជនជាប់ចោទការពារខ្លួនប្រឆាំងនឹងការចោទប្រកាន់របស់ការិយាល័យសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។ តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃការជំនុំជម្រះក្តី ត្រូវបានកម្រិតតែត្រឹមផលប្រយោជន៍ស៊ីវិលរបស់ខ្លួន និងត្រូវបកស្រាយយ៉ាងចង្អៀតត្រឹមតែតួនាទីនៃការ "ជួយគាំទ្រការចោទប្រកាន់"[២៨]។ បើទោះបីមានការបញ្ជាក់ថា ត្រូវតែគោរពសិទ្ធិរបស់ភាគីទាំងអស់ក៏ដោយ ក៏

---

[២៦] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៦-៤៧។

[២៧] *សូមមើលជាឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញាតទល់ នឹង Prlić និងអ្នកផ្សេងទៀត* សំណុំរឿងលេខIT-04-74-T Revised Version of the Decision Adopting Guidelines on Conduct of Trial Proceedings ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៦។

[២៨] *សូមមើល កថាខណ្ឌខាងលើ* កថាខណ្ឌ២។

00654998



សិទ្ធិរបស់ភាគីនីមួយៗ គឺអាស្រ័យលើតួនាទីរបស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធី។ ដូចនេះ ដើមបណ្តឹងរដ្ឋប្បវេណី ពុំមានសិទ្ធិក្នុងកិច្ចដំណើរការនីតិវិធីដូចគ្នាទៅនឹងសិទ្ធិរបស់ជនជាប់ចោទឡើយ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការជួយគាំទ្រការចោទប្រកាន់ "មិនផ្តល់សិទ្ធិទូទៅក្នុងការចូលរួមស្មើភាពគ្នាជាមួយនឹងសហព្រះរាជអាជ្ញានោះទេ"[២៩]។ ទោះបីដើមបណ្តឹងរដ្ឋប្បវេណីពុំមានភាពច្បាស់លាស់ក្នុងការកំណត់ថា តើខ្លួនចង់និយាយពីអ្វី នៅពេលអះអាងថា ខ្លួន "មានសមភាពស្មើគ្នាក្នុងការតទល់ក្តី" ពីព្រោះដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទមានសិទ្ធិផ្សេងៗគ្នានោះ បញ្ហានៃសមភាពនៃការតទល់ក្តីពុំកើតមានឡើយ។ មេធាវីការពារក្តីបានស្នើអង្គជំនុំជម្រះសាលាដំបូងឲ្យបង្កើតសេចក្តីណែនាំ ដែលបញ្ជាក់ពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនមែនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ពួកគាត់ឡើយ។

៦. នៅក្នុងកថាខណ្ឌ ៣ ដើមបណ្តឹងរដ្ឋប្បវេណីមានការភ័ន្តច្រឡំក្នុងការអះអាងដោយគ្មានសំអាងរបស់ខ្លួនថា ញត្តិនេះមិនបានរួមចំណែកដល់ការជំនុំជម្រះឲ្យបានឆាប់រហ័សទេ។ ញត្តិនេះបានបង្ហាញថា បើសិនជាគ្មានសេចក្តីណែនាំទេ នោះសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្នុងអំឡុងពេលមួយសមស្របនឹងត្រូវរងការរំលោភបំពាន។ ប្រសិនបើការណែនាំនេះមិនត្រូវបានបង្កើតឡើងនៅមុនសវនាការជំនុំជម្រះក្តី ដើម្បីធានាថា ភាគីទាំងអស់យល់ច្បាស់អំពីវិសាលភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេនោះ ពេលវេលាសម្រាប់ការជំនុំជម្រះក្តីនឹងត្រូវបានខ្ជះខ្ជាយដែលរំលោភដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីក្នុងពេលវេលាសមស្របមួយ[៣០]។ កង្វះសេចក្តីណែនាំនេះអាចនាំឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីច្រើនរូបសួរសំណួរដែលមិនស្ថិតនៅក្នុងវិសាលភាពនៃការត្រួតពិនិត្យ និងសួរសំណួរដដែលៗ ដែលធ្វើឲ្យរំលោភដល់សិទ្ធិរបស់ អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប[៣១]។

៧. ក្នុងកថាខណ្ឌ ៦ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា អង្គជំនុំជម្រះសាលាដំបូង "គ្មានយុត្តាធិការដើម្បីបង្កើតសេចក្តីណែនាំ ឬវិធានស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការជំនុំជម្រះក្តី ដោយកំណត់អំពីមធ្យោបាយក្នុងការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងហួសកម្រិតឡើយ"។ ទីមួយ

---

[២៩] សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង00១ កថាខណ្ឌ២៥។

[៣០] ញត្តិ កថាខណ្ឌ១៤។

[៣១] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ១៤-១៦។

ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានផ្ដល់អ្វីមួយសម្រាប់គាំទ្រការអះអាងរបស់ខ្លួន ដែលថា អង្គជំនុំជម្រះសាលាដំបូង ពុំមានយុត្តាធិការដើម្បីបង្កើតសេចក្ដីណែនាំស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតសេចក្ដីណែនាំ ដោយមិនចាំបាច់ធ្វើវិសោធនកម្មវិធានឡើយ ដែលបង្ហាញថា អង្គជំនុំជម្រះបានពិចារណាថា ខ្លួនមានយុត្តាធិការក្នុងការបង្កើតសេចក្ដីណែនាំនោះ[៣២]។ ទីពីរ ដូចមានបញ្ជាក់ខាងលើ សំណូមពររបស់មេធាវីការពារក្ដី នៅពេលខ្លួនបានស្នើអង្គជំនុំជម្រះសាលាដំបូងឲ្យបង្កើតសេចក្ដីណែនាំ មិនបញ្ចូលនូវការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងឡើយ កុំថាឡើងដល់ទៅការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងហួសកម្រិតនោះ[៣៣]។ ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានពន្យល់ថាហេតុអ្វីខ្លួនគិតថា ការបង្កើតសេចក្ដីណែនាំនេះចាំបាច់ត្រូវធ្វើវិសោធនកម្មវិធានផ្ទៃក្នុងនោះ។

៨. នៅក្នុងកថាខណ្ឌ ៨ ដើមបណ្ដឹងរដ្ឋប្បវេណីអះអាងថា លោក អៀង សារី មិនបានបង្ហាញថា តើសិទ្ធិរបស់ អៀង សារី ក្នុងការមានសមភាពក្នុងការតទល់ក្ដី និងសិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្រប នឹងត្រូវរងការរំលោភបំពានយ៉ាងដូចម្ដេចឡើយ ប្រសិនបើគ្មានសេចក្ដីណែនាំនោះ។ ផ្ទុយពីការអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ញត្តិបានបញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើគ្មានសេចក្ដីណែនាំអំពីដើមបណ្ដឹងរដ្ឋប្បវេណី សិទ្ធិរបស់ អៀង សារី ក្នុងការទទួលបានសមភាពនៃមធ្យោបាយក្នុងការតទល់ក្ដី និងការជំនុំជម្រះក្នុងពេលវេលាសមស្រប នឹងត្រូវរងការរំលោភបំពាន។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអនុវត្តតាមការបកស្រាយទូលំទូលាយលើវិធាន ២៣(១) នៃវិធានផ្ទៃក្នុង លោក អៀង សារី អាចប្រឈមទៅនឹងព្រះរាជអាជ្ញាច្រើននាក់ទៀត ដែលការប្រឈមនេះអាចជាការរំលោភសិទ្ធិរបស់ អៀង សារី ក្នុងការទទួលបានមធ្យោបាយតទល់ក្ដី ដែលមានសមភាព[៣៤]។

៩. នៅក្នុងកថាខណ្ឌ ៩ ដើមបណ្ដឹងរដ្ឋប្បវេណីបានលើកយោងដល់វិធាន ៩១ នៃវិធានផ្ទៃក្នុង ដែលចែងថា ភាគីទាំងអស់មានសិទ្ធិស្មើគ្នានៅចំពោះមុខ អ.វ.ត.ក។ មេធាវីការពារក្ដីមិនជំទាស់ទៅនឹងចំណុចថា វិធាន ៩១ នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ហើយ

[៣២] សេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០១ កថាខណ្ឌ២៦-៤៧។

[៣៣] *សូមមើល កថាខណ្ឌខាងលើ* កថាខណ្ឌ៣។

[៣៤] ញត្តិ កថាខណ្ឌ១០-១៣។

ដើមបណ្តឹងរដ្ឋប្បវេណីអាចសួរសំណួរ និងអាចជំទាស់ទៅនឹងសក្ខីកម្ម ដែលខ្លួនជឿថា សក្ខីកម្មនោះមិនរួមចំណែកដល់ការស្វែងរកការពិត។ ទោះជាយ៉ាងនេះក្តី សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗក៏ត្រូវបានកំណត់ដោយវិធាននានា និងច្បាប់ជាធរមាននៅ អ.វ.ត.កដែរ។ ដូចមានបញ្ជាក់ខាងលើស្រាប់ ច្បាប់ជាធរមាននៅ អ.វ.ត.ក ដាក់កម្រិតការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី[៣៥]។ ដូចនេះ វិធាន ៩១ ត្រូវតែបកស្រាយឲ្យជាផលប្រយោជន៍រដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

១០. នៅក្នុងកថាខណ្ឌ ១១ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ខ្លួនជួយដល់ការគាំទ្រដល់ការចោទប្រកាន់តាមរយៈការលើកឡើងពីអង្គហេតុទាក់ទងនឹងឈឺចាប់ និងផលវិបាករបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាទូទៅ បានជួបប្រទះ ហើយ "ដោយសារមូលហេតុនេះហើយទើប [ដើមបណ្តឹងរដ្ឋប្បវេណី] ចូលរួមដោយស្ម័យភាពក្នុងការសំដែងឲ្យឃើញនូវការពិត ដោយផ្តល់នូវសេចក្តីបំភ្លឺច្បាស់លាស់អំពីព្រឹត្តិការណ៍ និងធាតុផ្សំនៃភស្តុតាងដ៏ជឿជាក់មួយចំនួន ដែលជាជំនួយដល់ការចោទប្រកាន់"។ មេធាវីការពារក្តីឯកភាពជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែឯកភាពតែត្រង់ចំណុចណាមួយ ដែលច្បាប់ជាធរមាននៅ អ.វ.ត.ក អនុញ្ញាតប៉ុណ្ណោះ។ ដូចបានបញ្ជាក់ខាងលើ ច្បាប់ជាធរមាននៅ អ.វ.ត.ក ដាក់កម្រិតការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី[៣៦]។ ជនរងគ្រោះ ដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចជួយគាំទ្រការចោទប្រកាន់ឲ្យហួសពីអាណត្តិនេះឡើយ។ មេធាវីការពារក្តីនឹងមិនជំទាស់ទេ បើទោះបីជាវាផ្ទុយទៅនឹងវិធាន និងការអនុវត្តក្នុងតុលាការកម្ពុជា ដែលមានការបញ្ជាក់យ៉ាងច្បាស់ថា សកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកម្រិតត្រឹមតែផលប្រយោជន៍របស់ខ្លួន និងមិនមែនជាសាក្សីទេ[៣៧] ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើជាសាក្សី និងផ្តល់សក្ខីកម្មអំពីអ្វីដែលខ្លួនបានដឹងពីរឿងក្តី

[៣៥] *សូមមើល កថាខណ្ឌខាងលើ* កថាខណ្ឌ២។

[៣៦] *សូមមើល កថាខណ្ឌខាងលើ* កថាខណ្ឌ២។

[៣៧] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា៣១២ ចែងថា ៖ "ដើមបណ្តឹងរដ្ឋប្បវេណី មិនអាចត្រូវគេស្តាប់យកចម្លើយក្នុងឋានៈជាសាក្សីបានទេ"។

ព្រហ្មទណ្ឌ បន្ទាប់ពីគាត់បានធ្វើសម្បថរួចហើយ[៣៨]។ ក្នុងករណីនេះ ជនដែលផ្តល់សក្ខីកម្មនោះនឹងផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សី និងមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

១១. នៅក្នុងកថាខណ្ឌ ១២ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា "គោលបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺដើម្បីទទួលបានសំណងចំពោះព្យសនកម្មដែលខ្លួនបានទទួលរង ហើយវាឆ្លងកាត់ជាចាំបាច់ តាមរយៈការបង្ហាញអង្គហេតុ និងពិរុទ្ធភាពរបស់ជនជាប់ចោទទាក់ទងនឹងអង្គហេតុទាំងនោះ"។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី "ក្នុងការជំនុំជម្រះក្តីតាមពិតមិនត្រូវប្រែក្លាយទៅព្រះរាជអាជ្ញាបន្ថែមទៀតទេ"[៣៩]។ តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បី "បង្ហាញពីផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់ផលវិបាកមួយពីបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព"[៤០]។ ដើមបណ្តឹងរដ្ឋប្បវេណីមិនមែនជាអ្នកបង្ហាញពីពិរុទ្ធភាពទេ មានន័យថា ការបញ្ជាក់ពីពិរុទ្ធភាពគឺជាតួនាទីរបស់សហព្រះរាជអាជ្ញា"[៤១]។

១២. នៅក្នុងកថាខណ្ឌ ១៤ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងដោយភ័ន្តច្រឡំថា "ការបង្កើតមុខតំណែងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនដោះស្រាយវិសមភាពនៃមធ្យោបាយតទល់ក្តីដែលខ្លួនអះអាងថាជាជនរងគ្រោះដោយមិនបានបង្ហាញអំពីវិសមភាពនេះ"។ មេធាវីការពារក្តីបានផ្តល់ភស្តុតាងថា ការបង្កើតមុខតំណែងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះនៅតែមិនអាចដោះស្រាយការរំលោភបំពានលើសមភាពនៃមធ្យោបាយតទល់ក្តីរបស់ អៀង សារី ដដែល។ មេធាវីការពារក្តីបានរៀបរាប់ថា "សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅតែអាចទទួលបានជំនួយពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដូចជាតាមរយៈ "ការដាក់សារណា

---

[៣៨] *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/អជសដ សំណើរបស់ អៀង សារី ស្នើឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថប្រសិនបើត្រូវបានអនុញ្ញាតឱ្យផ្តល់សក្ខីកម្មអំពីអ្វីដែលពួកគាត់បានដឹងពីរឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ E57 ERN: 00647783-00647789។

[៣៩] សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០១ កថាខណ្ឌ២៦។

[៤០] វិធាន២៣*ស្ទួន*(១)(ខ)។

[៤១] វិធាន៨៧(១) ចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ"។

ផ្ទាល់មាត់ និង ជាលាយលក្ខណ៍អក្សរ ការស្តាប់ចម្លើយកូនក្តីរបស់ខ្លួន និងសាក្សី និងកិច្ចនីតិវិធីផ្សេងៗទៀត។ នេះហាក់បីដូចជាមិនបានហាមឃាត់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីច្រើននាក់មិនឱ្យស្តាប់ចម្លើយសាក្សីម្នាក់ៗឡើយ”[៤២]។ ចំណុចនេះមិនត្រូវបានទទួលការឆ្លើយតបពីដើមបណ្តឹងរដ្ឋប្បវេណីទេ។

១៣. នៅក្នុងកថាខណ្ឌ ១៥ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា “ការរួមផ្សំវិធាន១២ស្ទួនពីរ និងវិធាន៩១នៃវិធានផ្ទៃក្នុង អាចបញ្ជាក់យ៉ាងច្បាស់គ្រប់គ្រាន់អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនចាំបាច់បន្ថែមអ្វីផ្សេងទៀតឡើយ”។ ទីមួយ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានចែងបន្ថែមទៀតនៅក្នុងច្បាប់នានា ដែលមានជាធរមាននៅ អ.វ.ត.ក ដែលកម្រិតតួនាទី និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី[៤៣]។ ទីពីរ មេធាវីការពារក្តីមិនស្នើឱ្យបន្ថែមសិទ្ធិដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ។ មេធាវីការពារក្តីគ្រាន់តែស្នើអង្គជំនុំជម្រះសាលាដំបូងឱ្យបង្កើតសេចក្តីណែនាំ ដើម្បីការពារសិទ្ធិជាសារវន្តរបស់ អៀង សារី នៅក្នុងការជំនុំជម្រះប៉ុណ្ណោះ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានផ្តល់ការគាំទ្រដល់ការអះអាងរបស់ខ្លួន ដែលថា “ការបង្កើតសេចក្តីណែនាំនេះអាចប៉ះពាល់ ដែលមិនអាចអនុគ្រោះបានដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងដកហូតពីពួកគាត់នូវសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីឡើយ”។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានបញ្ជាក់ថាតើញត្តិនោះបានប៉ះពាល់ដល់សិទ្ធិណាមួយឡើយ។

១៤. នៅក្នុងកថាខណ្ឌ ១៦ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា មេធាវីការពារក្តី “បញ្ចេញនូវសម្មតិកម្មសុទ្ធសាធមួយថា ដើមបណ្តឹងរដ្ឋប្បវេណីរារាំងមិនឱ្យ [អៀង សារី ទទួលបានសិទ្ធិក្នុងការជំនុំជម្រះក្នុងអំឡុងពេលមួយសមស្រប] តាមអាកប្បកិរិយារបស់ពួកគេ ... [សម្មតិកម្មនេះមិនអាចចាត់ទុកជាភស្តុតាងទេ”។ មេធាវីការពារក្តីមិនអាចបង្ហាញភស្តុតាងជាក់ស្តែងឡើយ ពីព្រោះការជំនុំជម្រះមិនទាន់ចាប់ផ្តើមនៅឡើយទេ។ ពុំមានហេតុផលណាមួយដើម្បីរង់ចាំរហូតដល់ពេលចាប់ផ្តើមជំនុំជម្រះក្តីឡើយ។ តាមរយៈការបង្កើតសេចក្តីណែនាំ អង្គជំនុំជម្រះសាលាដំបូងអាចការពារសិទ្ធិជាសារវន្តរបស់ អៀង សារី ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដោយមិនបំពានដល់សិទ្ធិ

---

[៤២] ញត្តិកថាខណ្ឌ១៦ *ទាញសំអាងហេតុ* វិធាន១២*ស្ទួនពីរ*(៦)។

[៤៣] *សូមមើល កថាខណ្ឌខាងលើ* កថាខណ្ឌ២។

របស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការជំនុំជម្រះដោយយុត្តិធម៌ និងជៀសវាងការរំលោភបំពានធ្ងន់ធ្ងរដល់សិទ្ធិជាសារវ័ន្តរបស់ អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

១៥. នៅក្នុងកថាខណ្ឌ ១៧ ដើមបណ្ដឹងរដ្ឋប្បវេណីអះអាងថា មេធាវីការពារក្ដី "ព្យាយាមប្រៀបធៀបនីតិវិធីកម្ពុជា ផ្សារភ្ជាប់នឹងនីតិវិធីរបស់ អ.វ.ត.ក និងនីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ [("ICC")] ... នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិគ្មានដើមបណ្ដឹងរដ្ឋប្បវេណីឡើយ គឺមានតែជនរងគ្រោះប៉ុណ្ណោះ។ ដើមបណ្ដឹងរដ្ឋប្បវេណីមានការភ័ន្តច្រឡំក្នុងការអះអាងថា "ឋានៈទាំងពីរនេះមិនអាចច្រលំគ្នាបានឡើយ"។ ការប្រៀបធៀបជាមួយនឹង ICC គឺជាការប្រៀបធៀបសមស្របមួយ ពីព្រោះតុលាការនេះគឺជាតុលាការផ្សេងតែមួយគត់ ដែលជនុំជម្រះក្ដីចំពោះឧក្រិដ្ឋកម្ម ក្នុងកម្រិតមួយដូចគ្នានឹងរឿងក្ដីនៅ អ.វ.ត.ក និងបានអនុញ្ញាតឲ្យមានការចូលរួមពីជនរងគ្រោះ[៤៤]។ ផ្ទុយពីការអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង *Katanga*[៤៥] នៅ ICC អាចយកមកប្រើជាការណែនាំបាន។ អង្គជំនុំជម្រះក្នុងរឿងក្ដី *Katanga* បានសម្រេចថា "នៅពេលមានការបញ្ជាក់យ៉ាងច្បាស់ថា អន្តរាគមន៍របស់តំណាងផ្នែកច្បាប់ពុំមានទំនាក់ទំនងផ្ទាល់ជាមួយនឹងអត្ថប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះ ដែលមេធាវីនោះការពារទេនោះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមានអន្តរាគមន៍ឡើយ"[៤៦]។ បន្ទាប់មក អង្គជំនុំជម្រះបានបង្កើតសេចក្ដីណែនាំលម្អិតអំពីទម្រង់នៃការចូលរួមរបស់ជនរងគ្រោះ[៤៧]។ ករណីនេះគឺដូចគ្នានឹងទង្វើរបស់អង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក នៅពេលខ្លួនយល់ឃើញថា "ដោយសារតែច្បាប់បង្កើត អ.វ.ត.ក និងលក្ខណៈនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌមានកម្រិត ដែលអង្គជំនុំជម្រះសាលាដំបូងត្រូវតែទទួលស្គាល់នោះ វាតម្រូវឲ្យមានការបកស្រាយក្នុងន័យចង្អៀតអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក"[៤៨] ហើយក្រោយមកទៀត បានបង្កើត

---

[៤៤] ញត្តិថាខណ្ឌ១៧-២០។ លក្ខន្តិកៈICC មាត្រា៦៨(៣)។ វិធាន២៣។

[៤៥] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Katanga និង Ngudjolo Chui* សំណុំរឿងICC-01/04-01/07 សេចក្ដីសម្រេចលើបែបបទនៃការចូលរួមរបស់ជនរងគ្រោះ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០។

[៤៦] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៥៨។

[៤៧] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២៥-២៨។

[៤៨] សេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០១ កថាខណ្ឌ១៣។

សេចក្ដីណែនាំ[៤៩]។ ទាំង អ.វ.ត.ក ទាំង ICC ហាក់ដូចជាអនុវត្តតាមនីតិវិធីដូចគ្នាមួយ ហើយការណែនាំអាចស្វែងរកបានពី ICC។

១៦. នៅក្នុងកថាខណ្ឌ ១៨ ដើមបណ្ដឹងរដ្ឋប្បវេណីអះអាងថា មេធាវីការពារក្ដី "លើកឡើងពីការកម្រិត និងការរឹតត្បិតទៅលើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ចំណុចមួយចំនួន [ក្នុងចំណោមចំណុចផ្សេងៗ ដែលមេធាវីការពារក្ដីបានស្នើឱ្យពិចារណាបង្កើតសេចក្ដីណែនាំ] បានបើកចំហឱ្យមានការស្ដាប់ចម្លើយយ៉ាងយូរ រហូតទាល់តែធ្វើឱ្យដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀតមិនអាចផ្ដល់សក្ខីកម្មបាន..."។ មេធាវីការពារក្ដីមិនបានស្នើឱ្យមានសេចក្ដីណែនាំជាក់ស្ដែងឡើយនៅក្នុងញត្តិរបស់ខ្លួននោះ[៥០]។ ផ្ទុយទៅវិញ មេធាវីការពារក្ដីបានធ្វើសំណូមពរមួយចំនួនដល់អង្គជំនុំជម្រះសាលាដំបូងឱ្យធ្វើការពិចារណាលើសំណូមពរទាំងនោះ នៅពេលបង្កើតសេចក្ដីណែនាំនេះ។ ចំណុចដែលបានសំណូមពរ ឱ្យពិចារណាទាំងនេះអាចមានលក្ខណៈទូលំទូលាយ។ ទោះបីជាយ៉ាងនេះក្ដី អង្គជំនុំជម្រះសាលាដំបូងមានសេរីភាពក្នុងការបង្កើតសេចក្ដីណែនាំ ដែលមានលក្ខណៈសមស្របជាងចំណុចទាំងនេះ ទៅតាមតម្រូវការ។ ដូចបានបញ្ជាក់ខាងលើរួចហើយ មេធាវីការពារក្ដីមិនបានស្នើឱ្យមានការដកសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីណាមួយឡើយ។

១៧. នៅក្នុងកថាខណ្ឌ ១៩ មេធាវីការពារក្ដី "ស្នើសុំឱ្យមានសេចក្ដីណែនាំអនុវត្តមួយរឹតត្បិតសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្ដីសន្និដ្ឋានស្ដីពីការផ្ដន្ទាទោស និងសួរសំណួរទៅកាន់សាក្សី និងជនជាប់ចោទអំពីអត្តចរិតរបស់ជនជាប់ចោទ។ ក្រៅពីមិនអាចចេញជាសេចក្ដីណែនាំអនុវត្តបាននោះ សំណើបែបនេះផ្ទុយនឹងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី"។ ទីមួយ ការស្នើឱ្យមានសេចក្ដីណែនាំនេះមិនផ្ទុយនឹងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឡើយ។ ទីពីរ បើទោះបីជាមានសេចក្ដីណែនាំទាំងនេះក៏ដោយ ក៏ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានបញ្ជាក់ថា តើសំណូមពរ ដែលបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណានៅពេលបង្កើតសេចក្ដីណែនាំទាំងនេះ ផ្ទុយនឹងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងណាទេ។ សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែពិនិត្យ ដោយផ្ទៀងផ្ទាត់ជាមួយនឹងតួនាទីរបស់ពួកគេនៅ អ.វ.ត.ក។ តួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃ

[៤៩] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២៦-៤៧។

[៥០] ញត្តិកថាខណ្ឌ២១។

ការជំនុំជម្រះក្តី មានតិចតួច បើធៀបទៅនឹងតួនាទីរបស់ជនជាប់ចោទ[៥១]។ សំណូមពរដែលបានស្នើឡើងគឺស្របនឹងច្បាប់ដែលកំពុងអនុវត្តនៅ អ.វ.ត.ក ។ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតសេចក្តីណែនាំនៅក្នុងសំណុំរឿង ០០១ ៖ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានបដិសេធដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានបើក[៥២] ធ្វើសេចក្តីសន្និដ្ឋានស្តីពីការផ្តន្ទាទោស[៥៣] សាកសួរសាក្សី អ្នកជំនាញ និងសួរជនជាប់ចោទអំពីអត្តចរិតរបស់ជនជាប់ចោទ[៥៤]។ មេធាវីការពារក្តីមានការលំបាកក្នុងការកំណត់ថា តើសំណូមពរដែលបានស្នើឡើងនោះ ផ្ទុយនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងណានោះ។

១៨. នៅក្នុងកថាខណ្ឌ ២០ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា "មេធាវីការពារក្តីបានយោងទៅលើទឡ្ហីករណ៍ ដែលខ្លួនបានលើកឡើងនៅក្នុងសំណើរួម ចុះថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៩ ក្នុងសំណុំរឿង ០០១"។ មេធាវីការពារក្តីមិនបានដាក់សំណើរួម ចុះថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៩ នេះឡើយ។ មេធាវីការពារក្តីមិនមែនជាភាគីក្នុងសំណុំរឿង ០០១ ទេ។ ជាងនេះទៀត មេធាវីការពារក្តីមិនបានយោងទៅលើទឡ្ហីករណ៍ ដែលបានលើកឡើងក្នុងសំណើរួម ចុះថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៩ ទេ។

១៩. នៅក្នុងកថាខណ្ឌ ២០ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា មេធាវីការពារក្តី "យោងទៅលើមាត្រា ៣ (គ) និងមាត្រា ១២ (គ) នៃ "គោលការណ៍ជាសារវ័ន្ត និងការណែនាំទាក់ទងនឹងការធ្វើបណ្តឹង និងទាមទារសំណងរបស់ជនរងគ្រោះ ដោយសារការរំលោភជាក់ស្តែងនៃច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ [("សេចក្តីសម្រេច

[៥១] *សូមមើល កថាខណ្ឌខាងលើ* កថាខណ្ឌ២។

[៥២] *រឿងក្តី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អវតក/អជសង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ក្នុងការស្នើសុំធ្វើសេចក្តីសន្និដ្ឋានបើកពេលសវនាការលើអង្គសេចក្តី ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ ឯកសារ E23/4 ERN: 00293329-00293333។

[៥៣] សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០១ កថាខណ្ឌ៣៤-៣៥។

[៥៤] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ៤៥-៤៧។

UNGA")]"[៥៥]។ ដើមបណ្ដឹងរដ្ឋប្បវេណីអះអាងបន្ថែមទៀតថា "អត្ថបទនេះបានផ្ដល់យ៉ាងច្បាស់នូវលទ្ធភាពដល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការចូលរួមចំណែក ជាអាទិ៍ដល់ការកំណត់ទោសសមស្រប"។ ទីមួយ មេធាវីការពារក្ដីមិនធ្លាប់យោងទៅលើសេចក្ដីសម្រេច UNGA នៅក្នុងញត្តិឡើយ។ ទីពីរ សេចក្ដីសម្រេច UNGA មិនចងកាតព្វកិច្ចដល់ អ.វ.ត.ក ទេ។ ទីបី មាត្រា ៣(គ) និងមាត្រា ១២ (គ) នៃសេចក្ដីសម្រេច UNGA ចែងថា ៖

> មាត្រា ៣ ៖ កាតព្វកិច្ចគោរព ធានាឲ្យមានការគោរពដល់ និងអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ដូចមានចែងសម្រាប់សម្រាប់អនុវត្តដោយស្ថាប័នច្បាប់ពាក់ព័ន្ធ ដោយក្នុងនោះរួមមានទាំងភារកិច្ច ៖ (១) ផ្ដល់ឲ្យជនទាំងឡាយណា ដែលអះអាងថា ខ្លួនជាជនរងគ្រោះពីការរំលោភបំពានច្បាប់សិទ្ធិមនុស្ស ឬច្បាប់មនុស្សធម៌នូវលទ្ធភាពទទួលបានយុត្តិធម៌ស្មើគ្នា និងមានប្រសិទ្ធភាព ដូចមានការរាប់រាប់ដូចខាងក្រោម បើទោះបីជនទោះអាចជាអ្នកទទួលខុសត្រូវលើការរំលោភបំពានក៏ដោយ។
>
> មាត្រា ១២ ៖ ជនរងគ្រោះពីការរំលោភបំពានរួមនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឬការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវមានលទ្ធភាពស្មើៗគ្នាទទួលបានការដោះស្រាយតាមផ្លូវតុលាការយ៉ាងមានប្រសិទ្ធិភាព ដូចមានចែងនៅក្នុងច្បាប់អន្តរជាតិ។ ដំណោះស្រាយផ្សេងៗទៀតសម្រាប់ជនរងគ្រោះ មានដូចជា លទ្ធភាពទទួលបានការគាំទ្រពីស្ថាប័នរដ្ឋបាល និងស្ថាប័នផ្សេងៗ រួមទាំងយន្តការ ទម្រង់បែបបទ និងដំណើរការនីតិវិធី ស្របតាមច្បាប់ក្នុងប្រទេស។ ក្នុងន័យនេះ រដ្ឋជាសមាជិកគួរ ៖ (គ) ផ្ដល់ជំនួយដល់សមស្របដល់ជនរងគ្រោះ ដែលស្វែងរកភាពរកយុត្តិធម៌។

មាត្រា ៣(គ) និងមាត្រា ១២(គ)នៃសេចក្ដីសម្រេច UNGA នេះអាចជួយឲ្យជនរងគ្រោះទទួលបានយុត្តិធម៌ ប៉ុន្តែនេះមិនមែនមានន័យថា ដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើសេចក្ដីសន្និដ្ឋានស្ដីពីការផ្ដន្ទាទោសឡើយ។ នៅក្នុងសំណុំរឿង ០០១ នៅពេលមានការសាកសួរថាតើដើមបណ្ដឹងរដ្ឋប្បវេណី អាចធ្វើសេចក្ដីសន្និដ្ឋានស្ដីពីការផ្ដន្ទាទោសឬយ៉ាងណានោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វិធាន

[៥៥] គោលការណ៍ជាសារវ័ន្ត និងការណែនាំទាក់ទងនឹងការធ្វើបណ្ដឹង និងទាមទារសំណងរបស់ជនរងគ្រោះ ដោយសារការរំលោភជាក់ស្ដែងនៃច្បាប់អន្តរជាតិស្ដីពីសិទ្ធិមនុស្ស និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ A/Res/60/147, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦។

២៣(១)(ក) នៃវិធានផ្ទៃក្នុងមិនបានផ្តល់មូលដ្ឋានច្បាប់ណាមួយដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណី ធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសឡើយ[៥៦]។ ការលើកឡើងដូចនេះ ពីព្រោះថា "ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចចូលរួមដល់ការបង្ហាញការពិត ដោយការផ្តល់ព័ត៌មានជាក់ស្តែងទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទ។ ទោះជាយ៉ាងនេះក្តី ដើម្បីបណ្តឹងរដ្ឋប្បវេណីអាចបង្ហាញព័ត៌មានទាក់ទងនឹងសវតារ ដែលជួយដល់ការស្វែងរកការពិត"[៥៧]។

២០. នៅក្នុងកថាខណ្ឌ ២១ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គោលជំហររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចបដិសេធមិនឱ្យដើមបណ្តឹងរដ្ឋប្បវេណី តាំងសំណួរអំពីអត្តចរិតរបស់ជនជាប់ចោទ គឺ "ផ្ទុយនឹងការអនុវត្តពីមុនរបស់អង្គជំនុំជម្រះសាលាដំបូង .... ការកម្រិតលើចំណុចនេះ នៅក្នុងសំណុំរឿង ០០២ នឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី"។ ទីមួយ ការផ្តល់សំអាងហេតុដល់ការសម្រេចដូចនេះ គឺថា "គោលបំណងតែមួយគត់របស់ភស្តុតាងនេះ គឺជួយដល់អង្គជំនុំជម្រះសាលាដំបូងកំណត់បញ្ហាសម្រាប់ការផ្តន្ទាទោស ប្រសិនបើអាចធ្វើបាន"[៥៨]។ ចំណុចនេះគឺផ្ទុយទៅនឹងការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលថាគ្មានភស្តុតាងសម្រាប់ឱ្យអង្គជំនុំជម្រះសម្រេចដូចនេះ "ដោយសារ រយៈពេលច្រើនពេកក្នុងកិច្ចដំណើរការនីតិវិធីសម្រាប់តែ [សំណុំរឿត ០០១] ប៉ុណ្ណោះ"[៥៩]។ ទីពីរ អង្គជំនុំជម្រះសាលាដំបូងបានផ្លាស់ប្តូរការអនុវត្តរបស់ខ្លួននៅពាក់កណ្តាលនៃការជំនុំជម្រះក្តីសំណុំរឿង ០០១ ពីព្រោះខ្លួនទទួលស្គាល់ថា គំរូធម្មតានៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចែងនៅក្នុងយុត្តាធិការក្នុងប្រព័ន្ធច្បាប់ស៊ីវិល ត្រូវបានបង្កើតឡើងសម្រាប់ "កិច្ចដំណើរការនីតិវិធីមិនស្មុគស្មាញ និងមានជនរងគ្រោះតិច"[៦០]។ សំណុំ

---

[៥៦] សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០១ កថាខណ្ឌ៣៥។

[៥៧] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ៣៥។

[៥៨] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ៤៦។

[៥៩] ចម្លើយតប កថាខណ្ឌ២១។

[៦០] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អវតក/អជសង សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ E72/3 ERN: 00387022-00387047 កថាខណ្ឌ១២។

រឿង ០០១ ជាសវនាការលើការកែប្រែការឆ្លើយសារភាព និងមានដើមបណ្តឹងរដ្ឋប្បវេណី ចូលរួមសវនាការតែចំនួន ៩៣នាក់ប៉ុណ្ណោះ[៦១]។ សំណុំរឿង ០០២ គឺជាការជំនុំជម្រះដែលមានការតវ៉ាដោយមកដល់ពេលបច្ចុប្បន្នមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២.១២៣នាក់[៦២]។ ដូចនេះ រយៈពេលយ៉ាងមមាញឹកក្នុងសំណុំរឿង ០០១ អាចចាត់ទុកថាជារយៈពេលមិនសូវមមាញឹកការងារក្នុងសំណុំរឿង ០០២។ ទីបី មេធាវីការពារក្តីមិនបានស្នើសុំឱ្យធ្វើការដាក់កម្រិតលើផ្នែកនេះទេ ប៉ុន្តែខ្លួនបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងបង្កើតសេចក្តីណែនាំដើម្បីដោះស្រាយបញ្ហានេះ។ ទីបួន ដើមបណ្តឹងរដ្ឋប្បវេណីមិនបានពន្យល់ថា តើសិទ្ធិរបស់ខ្លួនត្រូវរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរយ៉ាងណាឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីមានការភ័ន្តច្រឡំក្នុងការអះអាងថា មតិជំទាស់របស់ចៅក្រម Lavergne អនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានលើ "គ្រប់បញ្ហាទាំងអស់ ដោយមិនធ្វើការបែងចែកថាតើបញ្ហានោះទាក់ទងនឹងអង្គហេតុ ឬទាក់ទងនឹងអត្តចរិត" ឡើយ។ ចៅក្រម Lavergne បានឯកភាពលើចំណុចទាំងអស់ ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចដែលថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចដាក់សារណាអំពីការកំណត់ទោស ឬសារណាផ្លូវច្បាប់ទាក់ទងនឹងការកំណត់ទោសបានទេ[៦៣]។ លោកចៅក្រម Lavergne គ្រាន់តែបានបញ្ចេញយោបល់ថា ៖ **ក.** ដើមបណ្តឹងរដ្ឋប្បវេណីគួរទទួលបានការអនុញ្ញាតឱ្យដាក់សារណាលើ ឬធ្វើការវាយតម្លៃអំពីកត្តានានា ដែលទាក់ទងនឹងសេចក្តីសម្រេចអំពីការកំណត់ទោស នៅពេលខ្លួនចង់និយាយពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទ ឬទាមទារឱ្យផ្តល់សំណង[៦៤] និង **ខ.** ដើមបណ្តឹងរដ្ឋប្បវេណីគួរទទួលបានការអនុញ្ញាតឱ្យតាំងសំណួរដល់ជនជាប់ចោទ ឬអ្នកជំនាញអំពីអត្តចរិតរបស់ជនជាប់ចោទ[៦៥]។

---

[៦១] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អវតក/អជសង សាលក្រមនៃសំណុំរឿង០០១ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ E188 ERN: 00572517-00572797 កថាខណ្ឌ៦៣៧។

[៦២] *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D427 ERN: 00604508-00605246 កថាខណ្ឌ១២។

[៦៣] សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០១ គំនិតខ្វែងយោបល់របស់ចៅក្រម Jean-Marc Lavergne, កថាខណ្ឌ១៩។

[៦៤] *ដូចដើងទំព័រខាងលើ។*

[៦៥] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ២០។

២១. នៅក្នុងកថាខណ្ឌ ២២ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា "ការកម្រិត និងរឹតត្បិតដែលស្នើឡើងដោយមេធាវីការពារក្តីលោក អៀង សារី គឺជាការប៉ះពាល់មិនអាចអនុគ្រោះបានដល់សិទ្ធិរបស់ភាគីមួយនៅក្នុងការជំនុំជម្រះក្តី .... ការកម្រិត និងការរឹតត្បិតបែបបនេះគឺជាការប្រព្រឹត្តរើសអើងចំពោះភាគីផ្សេងៗ ដែលមិនអាចទទួលយកបាន"។ ទីមួយ មេធាវីការពារក្តីបានស្នើដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបង្កើតសេចក្តីណែនាំដើម្បីបញ្ជាក់ឱ្យបានច្បាស់ពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការពារសិទ្ធិជាសារវន្តរបស់ អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ មេធាវីការពារក្តីមិនស្នើសុំឱ្យមានការដាក់កម្រិត និងរឹតត្បិតឡើយ។ ទីពីរ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានបញ្ជាក់ថា តើសេចក្តីណែនាំទាំងនេះធ្វើឱ្យប៉ះពាល់លើសិទ្ធិរបស់ខ្លួនយ៉ាងណាទេ។ ទីបី មានការបែងចែកយ៉ាងច្បាស់លាស់នៅក្នុងវិធាន ទាក់ទងនឹងតួនាទីរបស់ភាគីនីមួយៗ ក្នុងអំឡុងពេលជំនុំជម្រះ។ ការកម្រិត និងការរឹតត្បិត ដែលជាការប្រព្រឹត្តិដោយរើសអើងក្នុងចំណោមភាគីផ្សេងៗ គឺអាចទទួលយកបាន ក្នុងករណីមានការដាក់កម្រិតដល់តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី បើធ្វើការប្រៀបធៀបជាមួយនឹងតួនាទីរបស់ជនជាប់ចោទនោះ[៦៦]។

## III. សេចក្តីសន្និដ្ឋាន

២២. មេធាវីការពារក្តីទទួលស្គាល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងគាំទ្រការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីថាជាផ្នែកមួយដ៏សំខាន់នៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ជាពិសេសនៅ អ.វ.ត.ក។ ទោះជាយ៉ាងនេះក្តី សេចក្តីណែនាំនេះគឺជាតម្រូវការដ៏ចាំបាច់ដើម្បីលុបបំបាត់ភាពមិនច្បាស់លាស់នៅក្នុងវិធាននានា និងដើម្បីកំណត់ឱ្យច្បាស់លាស់ពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២។ បើសិនជាគ្មានសេចក្តីណែនាំសមរម្យ និងមានការបញ្ជាក់ច្បាស់លាស់ទេ សិទ្ធិជាសារវន្តរបស់ អៀង សារី ក្នុងការទទួលបាននូវសមភាពនៃមធ្យោបាយតទល់ក្តី និងការទទួលបាននូវការជំនុំជម្រះក្តីក្នុងពេលវេលាសមរម្យ អាចត្រូវបានរំលោភបំពាន។ មេធាវីការពារក្តីបន្តស្នើថា បញ្ហានេះគួរតែយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ដែលនឹងគ្រោងធ្វើឡើងនៅខែមេសា ឆ្នាំ២០១១ ដើម្បីឱ្យភាគីទាំងអស់បញ្ចេញគំនិតរៀងៗគ្នានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកចម្លើយតបនេះដោយក្តីគោរព។

---

[៦៦] *សូមមើល កថាខណ្ឌខាងលើ* កថាខណ្ឌ២។

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក អៀង សារី

បានចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១១